# ពិធីចុះហត្ថលេខាលើកំណត់ហេតុពិភាក្សាស្តីពីការកំណត់ការសិក្សា ដើម្បីអភិវឌ្ឍន៍គម្រោងពង្រីក និងស្តារប្រព័ន្ធផ្គត់ផ្គង់ទឹកស្អាត នៅខេត្តកំពត និងខេត្តព្រះសីហនុ



យោងតាមការស្នើសុំរបស់រាជរដ្ឋាភិបាលកម្ពុជានូវជំនួយឥតសំណងពីរាជរដ្ឋាភិបាលជប៉ុន តាមរយៈទីភ្នាក់ងារកិច្ចសហប្រតិបត្តិការអន្តរជាតិនៃប្រទេសជប៉ុនហៅកាត់ថាៈ JICA ដើម្បីអភិវឌ្ឍន៍គម្រោងពង្រីក និងស្តារប្រព័ន្ធផ្គត់ផ្គង់ទឹកស្អាត នៅខេត្តកំពត និងក្រុងព្រះសីហនុ រាជរដ្ឋាភិបាលជប៉ុនបានចាត់បញ្ជូនក្រុមសិក្សារៀបចំគម្រោង ដើម្បីពិនិត្យសិក្សាលើគម្រោងពង្រីក និងស្តារប្រព័ន្ធផ្គត់ផ្គង់ទឹកស្អាត នៅខេត្តកំពត និងខេត្តព្រះសីហនុ ហើយត្រូវរាយការណ៍ដោយជំនាញការជប៉ុន នៅរសៀលថ្ងៃទី១០ ខែមិថុនា ឆ្នាំ២០១៤ ក្នុងជំនួបរវាង ឯកឧត្តម **ចម ប្រសិទ្ធ** ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម និងសិប្បកម្ម និង ក្រុមជំនាញការអង្គការ JICA ជប៉ុន ដឹកនាំដោយលោក **IWASAKI Eiji** អគ្គនាយករងសម្រាប់កិច្ចការធនធានទឹក និងការគ្រប់គ្រងគ្រោះមហន្តរាយ នៃនាយកដ្ឋានបរិស្ថានសកល នៃអង្គការ JICA នៅទីស្តីការក្រសួង នូវលទ្ធផលដូចខាងក្រោមៈ





-**ចំពោះគម្រោងគម្រោងទឹកស្អាតខេត្តកំពត** គឺៈ**ទី១**-ពង្រីកសមត្ថភាពផលិតកម្ម ១០.០០០ ម៉ែត្រគូប ក្នុងមួយថ្ងៃ ពីលើផលិតកម្មមានស្រាប់ **ទី២**-ពង្រីកបណ្តាញថ្មី ៣៥ គ.ម និងប្តូរបណ្តាញចាស់សល់ពីជំនាន់បារាំង ១៥ គ.ម សរុប ៥០គ.ម **ទី៣**-បំពាក់ឧបករណ៍ និងសម្ភារៈសម្រាប់ដំណើរការ និងថែរក្សាប្រព័ន្ធផលិតកម្មថ្មី ។ -**សម្រាប់ខេត្តព្រះសីហនុ** គឺៈ**ទី១**-ស្មើស្តារធ្វើច្រាំងជើងទេរ និងរបងបឹងព្រែកទប់ និង **ទី២**-ពង្រីកបណ្តាញថ្មីប្រវែង ១៨ គ.ម និងផ្លាស់ប្តូរបណ្តាញចាស់ ចំនួន ៧គ.ម សរុប ២៥ គ.ម ។ ក៏ប៉ុន្តែ ក្រោយលទ្ធផលការសិក្សា ជំនាញការជប៉ុនបានពិនិត្យឃើញថាៈ បឹងព្រែកទប់ ទោះបីស្តារហើយក៏នៅមានលក្ខណៈតូចនៅឡើយ មិនអាចផ្គត់ផ្គង់គ្រប់តាមតម្រូវការ ។ ដូច្នេះ ភាគីជប៉ុននឹងសិក្សាអំពីលទ្ធភាពប្រភពទឹកដែលមានស្រាប់ និងប្រភពទឹកថ្មីដែលនៅក្បែរក្រុង ដើម្បីបំពេញឱ្យតម្រូវការដល់ឆ្នាំ ២០៣០ រួមមានៈ បឹងព្រែកទប់ (រួមទាំងសណ្ឋានបាតបឹង)-ទំនប់ក្បាលឆាយ-ទំនប់បង្វៀរ ហ៊ុន សែន ស្ទឹងហាវ-អាងទឹកបត់គគីរ(ទំបន់អូរចំណារ) និងប្រភពទឹកក្រោមដី ។ ការសិក្សានេះនឹងត្រូវពន្យាពេលរហូតដល់ចុងឆ្នាំ២០១៤ ខាងមុខ ។




មានប្រសាសន៍នាឱកាសនោះ ឯកឧត្តម ទេសរដ្ឋមន្ត្រី **ចម ប្រសិទ្ធ** បានសម្តែងនូវអំណរគុណ ចំពោះរាជរដ្ឋាភិបាលជប៉ុន ដែលបានផ្តល់ជំនួយអភិវឌ្ឍន៍ជាច្រើនដល់កម្ពុជា ។ ក្នុងនោះជំនួយសម្រាប់ពង្រីកប្រព័ន្ធនិង ការផ្គត់ផ្គង់ទឹកស្អាតនៅកម្ពុជា រហូតដល់កម្ពុជាទទួលបានពានរង្វាន់ជាអន្តរជាតិលើវិស័យទឹកស្អាតជាបន្តបន្ទាប់ជូនដល់រដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ គឺមិនអាចកាត់ផ្តាច់ពីជំនួយរបស់រាជរដ្ឋាភិបាលជប៉ុន និងអ្នកបច្ចេកទេសនៃអង្គការ JICAជប៉ុន បានឡើយ ។ ដូច្នេះ ភាពជោគជ័យលើវិស័យទឹកស្អាតនៅកម្ពុជា ប្រជាជនកម្ពុជាពិតជាមិនភ្លេចនូវគុណបំណាច់របស់ប្រទេសជប៉ុន និងនៅតែត្រូវការដៃគូរជប៉ុនលើវិស័យនេះបន្តទៀត ។

ដើម្បីអនុវត្តគម្រោងនេះឱ្យបានជោគជ័យ ឯកឧត្តម **ចម ប្រសិទ្ធ** ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម និងសិប្បកម្ម តំណាងរាជរដ្ឋាភិបាលកម្ពុជា និងលោក **IWASAKI Eiji** អគ្គនាយករងសម្រាប់កិច្ចការធនធានទឹក និងការគ្រប់គ្រងគ្រោះមហន្តរាយ នៃនាយកដ្ឋានបរិស្ថានសកល នៃអង្គការ JICA បានចុះហត្ថលេខាលើកំណត់ហេតុពិភាក្សាស្តីពីការកំណត់ការសិក្សា ដើម្បីអភិវឌ្ឍន៍គម្រោងពង្រីក និងស្តារប្រព័ន្ធផ្គត់ផ្គង់ទឹកស្អាត នៅខេត្តកំពត និងខេត្តព្រះសីហនុ ប្រកបដោយបរិយាកាសរីករាយបំផុត ។